ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០ អនក្រ.បក

# អនុក្រឹត្យ

ស្តីពី

ការទទួលស្គាល់វិទ្យាស្ថានអាស៊ីប៉ាស៊ីហ្វិច

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អន.ក្រ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពី ការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពី លក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំ របស់លោក ណៃ វ៉ង់ដា ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០២
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា ១ :** ទទួលស្គាល់ គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **"វិទ្យាស្ថានអាស៊ីប៉ាស៊ីហ្វិច"** **"Asia Pacific Institute"** ហៅកាត់ជាភាសាខ្មែរ "វ.អ.ប" និងហៅកាត់ជាភាសាអង់គ្លេស

"A.P.I" ។ វិទ្យាស្ថាននេះ ស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និង កីឡា និង មានទីតាំងគោល នៅអាគារលេខ ១៨៩ វុក្ខវិថីម៉ៅសេទុង សង្កាត់ទួលស្វាយព្រៃទី ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

មាត្រា ២ : វិទ្យាស្ថានអាស៊ីប៉ាស៊ីភិច ធ្វើការបណ្តុះបណ្តាល :

- ថ្នាក់បរិញ្ញាប័ត្ររង សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៨០ ក្រេឌីត ជាមធ្យម ។
- ថ្នាក់បរិញ្ញាប័ត្រ សិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ ត្រូវនឹង ១៦០ ក្រេឌីត ជាមធ្យម ។

បច្ចុប្បន្ននេះ វិទ្យាស្ថានអាស៊ីប៉ាស៊ីភិច មានមហាវិទ្យាល័យភាសាបរទេស ដែលធ្វើការបណ្តុះបណ្តាលលើឯកទេស : អប់រំផ្នែកភាសាអង់គ្លេស (Teaching English as a Foreign Language) ភាសាអង់គ្លេស និង ការបកប្រែភាសាអង់គ្លេស ( Interpretation and Translation) ។ ទៅពេលអនាគត វិទ្យាស្ថានអាស៊ីប៉ាស៊ីភិច អាចបើកមហាវិទ្យាល័យ ឬ សាខា ឬឯកទេស ឬកំរិត ឬប្រភេទបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ៣ : វិទ្យាស្ថានអាស៊ីប៉ាស៊ីភិច មានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារពិនិត្យ និង សំរេច លើគោលនយោបាយ និង ផែនការអភិវឌ្ឍរបស់វិទ្យាស្ថាន និង មានក្រុមប្រឹក្សាសិក្សាមួយ សំរាប់ពិនិត្យ លើកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

មាត្រា ៤ : លក្ខខណ្ឌទទួលសិស្សអោយចូលរៀន :

- ថ្នាក់បរិញ្ញាប័ត្ររង : បេក្ខជនត្រូវមាន ចំណេះដឹងទាបបំផុត បានសិក្សាបញ្ចប់ថ្នាក់ទី ១២ នៃមធ្យមសិក្សាចំណេះទូទៅ ។
- ថ្នាក់បរិញ្ញាប័ត្រ : បេក្ខជនត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។

វិទ្យាស្ថាន ត្រូវគោរពតាមបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និង កីឡា ដែលកំនត់អំពីការជ្រើសរើសនិស្សិតអោយចូលរៀន នៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

មាត្រា ៥ : នាយក វិទ្យាស្ថានអាស៊ីប៉ាស៊ីភិច មានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងវិទ្យាស្ថាន ។
- ជ្រើសរើសសិស្ស-និស្សិតអោយចូលរៀន និងជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អ នូវការងារនិស្សិត ការងារសិក្សា ការងារបង្រៀន ការងារស្រាវជ្រាវ ការប្រលង និង ការប្រគល់សញ្ញាប័ត្រ ។

- គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំរបស់រាជរដ្ឋាភិបាល និង របស់ក្រសួងអប់រំ យុវជន និង កីឡា ។
- ធានាអោយបាននូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សាជូនទាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជននិងកីឡា រាល់ឆមាសទីមួយៗ អោយបានទៀងទាត់តាមការកំណត់ ។

**មាត្រា ៦ :** និស្សិត ដែលរៀនចប់កម្មវិធីសិក្សា របស់វិទ្យាស្ថានអាស៊ីប៉ាស៊ីភិច និង ទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រ តាមកំរិត ដែលបានសិក្សា ។ សញ្ញាប័ត្រនេះ ត្រូវបានផ្តល់អោយដោយ វិទ្យាស្ថានអាស៊ីប៉ាស៊ីភិច ហើយត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និង កីឡា ក្នុងករណីវិទ្យាស្ថាននេះ បំពេញ និង អនុវត្តបាន តាមគោលការណ៍កំនត់ របស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និង វិទ្យាស្ថានអាស៊ីប៉ាស៊ីភិច មានភារកិច្ច រៀងៗខ្លួន ដើម្បីអនុវត្តនិងប្រតិបត្តិ តាមអនុក្រឹត្យនេះ ។

**មាត្រា ៨ :** អនុក្រឹត្យនេះ មានប្រសិទ្ធិភាព គតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ

"ដើម្បីជ្រាប"

- ដូចមាត្រា ៧ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ